# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារ សាកលវិទ្យាល័យបាត់ដំបង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតសាកលវិទ្យាល័យបាត់ដំបង
- បានឃើញសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** បង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ស ខេង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម ហុក ឡុងឌី | អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្តម ប្រាជ្ញ ចន្ទ | អភិបាលខេត្តបាត់ដំបង | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម ពិត ចំណាន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៥- ឯកឧត្តម ម៉ម សុផាណា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៦- | ឯកឧត្តម ឌុល គឿន | អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ៧- | ឯកឧត្តម ចិន ឃន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ | សមាជិក |
| ៨- | ឯកឧត្តម ឌូច ម៉ារឹម | អភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៩- | ឯកឧត្តម នាយ សាររឹត | អភិបាលខេត្តពោធិ៍សាត់ | សមាជិក |
| ១០- | ឯកឧត្តម ឈាំ ឌុំ | អភិបាលខេត្តកំពង់ធំ | សមាជិក |
| ១១- | ឯកឧត្តម ចក់ ឡេង | ប្រធាននាយកដ្ឋានភស្តុភារ សំភារៈ និងបច្ចេកទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ១២- | ឯកឧត្តម អ៊ី ឈាន | អភិបាលក្រុងប៉ៃលិន | សមាជិក |
| ១៣- | ឯកឧត្តម អ៊ុយ ស៊ីម | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | សមាជិក |
| ១៤- | ឯកឧត្តម ចាន់ ណាររឹត | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ១៥- | ឯកឧត្តម មាស សារឹម | ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង | សមាជិក |
| ១៦- | ឯកឧត្តម ជា អឿន | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ចក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៧- | ឯកឧត្តម អ៊ុក វឌ្ឍ | អភិបាលរងខេត្តបាត់ដំបង | សមាជិក |
| ១៨- | លោក ម៉ក់ ង៉ុយ | អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សាក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩- | លោក ឡាយ បូរិន | ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២០- | លោក អ៊ុយ រី | អភិបាលស្រុកបាត់ដំបង | សមាជិក |
| ២១- | លោក យូ ទីះ | អនុប្រធាននាយកដ្ឋានឧត្តមសិក្សាក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២២- | លោក ឆេរី ប្រុង | នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបង | សមាជិកអចិន្ត្រៃយ៍ |
| ២៣- | លោក ម៉េរ ម៉ើ | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង | សមាជិក |
| ២៤- | លោក ខួន តេនះ | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី ខេត្តបាត់ដំបង | សមាជិក |
| ២៥- | លោក គុប គាន់លាង | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង | សមាជិក |
| ២៦- | លោក រេចខ រីឡូ | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី ខេត្តបាត់ដំបង | សមាជិក |
| ២៧- | លោក ថុក ម៉ិនឆឿន | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង | សមាជិក |
| ២៨- | លោកឧកញ៉ា ទ៉ុក ជូរ | | សមាជិក |

ប្រការ ២.- គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- អំពាវនាវរកជំនួយឧបត្ថម្ភជាសំភារៈ និងថវិកាពីសប្បុរជននានា សំរាប់ការសាងសង់សាកលវិទ្យាល័យ
- សិក្សា និងលើកគំរោងនៃសំណង់អាគារ និងចាត់ចែងការសាងសង់
- ចាត់ចែង គ្រប់គ្រងសំភារៈសំណង់ និងត្រួតពិនិត្យការសាងសង់

www.pheakdeylaw.com

- ចាត់ចែង ត្រួតពិនិត្យសំណង់ និងការបំពាក់គ្រឿងបង្គំនៃសំណង់ និងគ្រឿងសង្ហារឹមនានា ។

**ប្រការ ៣.-** អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានប្រចាំការ ។

**ប្រការ ៤.-** សេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៧

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- សាលាខេត្ត ក្រុងពាក់ព័ន្ធ
- ដូចចែងក្នុងប្រការ ៥
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com